ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ADB

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាព ជុំវិញតំបន់ទន្លេសាប ( TA 7305-CAM )

# សៀវភៅកំណត់ត្រាគ្រប់គ្រងកសិដ្ឋានកសិករ

កសិករ: ..........................................................................................

ភូមិ: ..........................................................................................

ឃុំ: ..........................................................................................

ស្រុក: ..........................................................................................

ខេត្ត: ..........................................................................................

ខែ មេសា ឆ្នាំ ២០១៣

សូមទុកដីដូចជាឆ្នាំងបាយមួយ
ដែលអាចស្លសម្លបានច្រើនមុខ

មានរោងជីកំប៉ុស្តមួយ
ដូចមានរោងចក្រជីមួយនៅក្បែរផ្ទះ

វស្សាចប់ហើយ ចូរកុំកន្តើយ
នាំគ្នាធ្វើប្រាំង ញាប់ដៃញាប់ជើង
ប្រឡងប្រណាំង ទើបផលស្រូវប្រាំង
យើងបានជោគជ័យៗ

អនុសាសន៍ឯកឧត្តមបណ្ឌិត **ចាន់ សារុន**
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


NIDA
ADB
WELCOME TO
THE OFFICIAL INAUGURATION OF TELECENTER
PRESIDED OVER BY H.E Dr. CHAN SARUN, MINISTER OF
AGRICULTURE, FORESTRY AND FISHERIES/















# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ ទន្លេសាប (TSTD) ផ្តល់សហ-ហិរញ្ញប្បទានសម្រាប់អនុវត្តដោយរដ្ឋាភិបាលហ្វាំងឡង់ មូនិធីជៃគូអ៊ី-អាស៊ី និង ពុទ្ធិ នៃសាធារណរដ្ឋកូរ៉េ ធនាគារអភិវឌ្ឍន៍អាស៊ី និង រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងនេះ អនុវត្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង អាជ្ញាធរជាតិទទួលបន្ទុកអភិវឌ្ឍន៍វិស័យ បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មានវិទ្យា។ គម្រោង បានធ្វើការសាកល្បងលើ ការធ្វើបង្ហាញ និង បណ្តុះបណ្តាលបច្ចេកវិទ្យាកសិកម្ម ក៏ដូចជា ការផ្តល់សេវាព័ត៌មានជនបទ (តាមរយៈ មណ្ឌល ព័ត៌មានកសិករជនបទ) ដើម្បីបង្កើន និង ពង្រីកប្រភពចំណូលគ្រួសារកសិករខ្នាតតូច ក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។ ផ្នែកសំខាន់ទាំង ២ របស់ គម្រោង គឺៈ

១-ការបណ្តុះបណ្តាល និង បង្ហាញបច្ចេកវិទ្យា និងការអនុវត្តន៍បច្ចេកទេសកសិកម្ម
២-ការសាកល្បងផ្តល់សេវាព័ត៌មានអេឡិចត្រូនិចជនបទ

គម្រោងបានប្រមូលផ្តុំ និង ចងក្រងឯកសារបច្ចេកទេសកសិកម្ម ដែលអាចរកបាននៅ តាម **មណ្ឌលព័ត៌មានកសិករជនបទ** ក្នុងខេត្តទាំងបួន និង តាមរយៈប្រព័ន្ធកុំព្យូទ័រ ដែលមាន អាសយដ្ឋាន (វេបសាយ) www.telecentercambodia.org/ ។

សៀវភៅកំណត់ត្រាកសិករនេះ ត្រូវបានរៀបចំឡើងដោយក្រសួងកសិកម្ម សំដៅជួយ កសិករ ក្នុងការកត់ត្រានូវព័ត៌មានជាក់លាក់ ស្តីពីការប្រើប្រាស់ធនធាន និង ផលិតកម្ម ដើម្បីជា មូលដ្ឋានធ្វើការសម្រេចចិត្តបានត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ ។ កសិករអាចប្រើកូនសៀវភៅនេះ សម្រាប់កត់ត្រាព័ត៌មានគន្លឹះៗ (ចំណូល និង ចំណាយ - រួមទាំង ពលកម្មគ្រួសារ) ទាក់ទងនឹង ការអនុវត្តន៍បច្ចេកទេសណាមួយ ដែលបានរៀនសូត្រពីកម្មវិធីផ្សព្វផ្សាយ / ការបណ្តុះបណ្តាល តាមមូលដ្ឋាន និងសម្រាប់កត់ត្រាការងារផលិតកម្មគ្រួសារផ្សេងទៀត។

មានព័ត៌មានជាក់លាក់-ត្រឹមត្រូវក្នុងដៃ អាចនាំទៅដល់ការបង្កើតបាននូវ ពុទ្ធិ (ចំណេះ) ច្បាស់លាស់។ ចំណេះ ជាប្រភពផ្តល់អំណាច - ក្នុងការសំរេចចិត្តបានត្រឹមត្រូវ (អ្វីដែលល្អ ត្រូវធ្វើ បានចំណេញ) និង ជម្រើសរបរជីវភាពគ្រួសារ ។ សង្ឃឹមថា កូនសៀវភៅនេះ អាចជួយ អំ ពូ-មីង ក្នុងការតម្រង់ទិស ឆ្ពោះទៅរកជោគជ័យ។

# **សេចក្តីផ្តើម**

ការកត់ត្រាទុកពី **ចំណាយ** និង **ចំណូល** មានសារៈសំខាន់ណាស់។ ហេតុផលចំបងមួយចំនួន ដែលចាំបាច់ ត្រូវឱ្យយើងកត់ត្រាជាប្រចាំពី ចំណាយ និង ចំណូល មានដូចតទៅ ៖

- បើគ្មានការកត់ត្រាពីអ្វីដែលបានចំណាយ ហើយអ្វីដែលបានចំណូលនោះទេ យើងនឹងមិនអាចដឹងបានទេ ថាតើមុខជំនួញរបស់យើងខាត ឬ ចំណេញ? ចូរចងចាំថា ការទទួលបានប្រាក់ចំណូលរាល់ថ្ងៃ មិនមានន័យថា យើងសុទ្ធតែបានទទួលប្រាក់ចំណេញនោះទេ ។
- បើយើងដឹងច្បាស់ពីមុខចំណាយ និង មុខចំណូលច្បាស់លាស់ យើងអាចរិះរកវិធីដើម្បីគ្រប់គ្រងជំនួញ ឲ្យបានកាន់តែល្អ និង កាន់តែបានចំណេញច្រើន ។
- កំណត់ត្រាស្តីពីចំណាយ - ចំណូល អាចប្រើប្រាស់សម្រាប់ធ្វើផែនការចំណាយនៅពេលអនាគត ព្រោះយើងអាចដឹងពីតម្លៃ និង ធនធាន ដែលត្រូវចំណាយ ។

គោលដៅចំបងនៃការធ្វើជំនួញ ឬ ផលិតកម្មអ្វីមួយ ដើម្បីរកបានចំណេញ និង កាន់តែបានចំណេញច្រើនឡើង។ **ប្រាក់ចំណេញ** ជាផលសង (ឬ ភាពខុសគ្នាជាវិជ្ជមាន) រវាង **ទឹកប្រាក់ចំណូលសរុប** (បានមកពីលក់ផលិតផល ឬ សេវាកម្ម) និង **ទឹកប្រាក់ចំណាយសរុបទាំងអស់**។ ចំណាយ អាចបែងចែកជា ២ ប្រភេទ គឺ ៖

### ១. **ចំណាយមិនប្រែប្រួល**[1]

គឺជា ចំណាយមូលធន ដូចជា ដី សំណង់ ឃ្លាំង ទ្រុងមាន់ ទូភ្ញាស់ពងមាន់...... ដែលមានតម្លៃ (ត្រូវកាត់រំលស់) ជាប្រចាំ ទោះជាមានការផលិត ឬគ្មាន ក៏ដោយ ។ ដោយសារឧបករណ៍ និង សម្ភារៈនៅក្នុងមុខចំណាយមិនប្រែប្រួលទាំងនេះ អាចប្រើ បានច្រើនដង (គឺថា ប្រើម្តង មិន

---

[1] នៅពេលទិញ ឬ សាងសង់ហើយ (គឺថា បានចំណាយហើយ) ទោះបីប្រើ ឬ មិនប្រើក្តី សម្រាប់ការផលិតទំនិញ (ផលិតផល) អ្វីមួយ ក៏ដោយ ក៏គុណភាព (គឺថា វាក្លាយបន្តិចម្តងៗ ទៅជារបស់ចាស់ សឹករេចរិល ......) ហើយ តំលៃរបស់វា ក៏នឹងត្រូវបាត់បង់ បន្តិចម្តងៗ ទៅតាមនោះដែរ។

អស់) ហើយ អាចប្រើនៅក្នុងផលិតកម្មសារក្រោយៗទៀតនោះ គេត្រូវគិតរំលស់វា ជាច្រើនដង/សារ។ ការកំណត់ចំនួនសាររំលស់ថ្លៃឧបករណ៍ និង សម្ភារៈក្នុងប្រភេទចំណាយមិនប្រែប្រួលនេះ អាចគិតបានច្រើនបែប ដូចជា តាមចំនួនសារ (ដង) ផលិតកម្ម តាមអាយុកាល (រយៈពេល) អាចនៅប្រើបានរបស់វា ...។

២. ចំណាយប្រែប្រួល

ជាប្រភេទចំណាយជាក់ស្តែងសម្រាប់ការផលិតនូវផលិតផល ឬ សេវាអ្វីមួយ ។ ចំណាយប្រភេទនេះ រួមមាន វត្ថុធាតុដើម ដូចជា ចំណី វ៉ាក់សាំង ថ្នាំព្យាបាល កំបោរស ការរៀបចំដី ពលកម្ម ... ដែលត្រូវការចាំបាច់សម្រាប់ផលិតមុខទំនិញ ឬ ផលិតផលអ្វីមួយ (ដូចជា ស្រូវ មាន់ ជ្រូក...) ។

ដើម្បីឲ្យដឹងច្បាស់ ថាតើគោលដៅជោគជ័យជំនួញ បានសម្រេចត្រឹមណានោះ គេត្រូវការព័ត៌មានជាចាំបាច់ ដែលមិនអាចរកបាន ក្រៅពីការកត់ត្រាជាប្រចាំ និង បានត្រឹមត្រូវរបស់យើងនោះឡើយ ។ ការកត់ត្រាអាចផ្តោតលើការប្រមូលព័ត៌មានចាំបាច់ សម្រាប់វិភាគចំណាយ និង ចំណេញ និង តម្រង់ទិសមុខរបរ ឬ ផលិតកម្មតាមពេលវេលាឲ្យចំ ឆ្លើយតបតម្រូវការទីផ្សារ និង ទៅអនាគតខាងមុខ។ តារាងនៅទំព័រខាងមុខៗនេះ ជាទម្រង់កត់ត្រាសាមញ្ញមួយ ដែលកសិករ (អ្នកដាំដំណាំ ឬ អ្នកចិញ្ចឹមសត្វ) អាចប្រើសម្រាប់កត់ត្រាចំណាយ ចំណូលរបស់ខ្លួន ។

៣. ប្រាក់ចំណេញ

ប្រាក់ចំណេញ ជាផលសង/ដក (ឬ ភាពខុសគ្នាជាវិជ្ជមាន) រវាង ទឹកប្រាក់ចំណូលសរុប (បានមកពីលក់ផលិតផល ឬសេវាកម្ម) និង ទឹកប្រាក់ចំណាយសរុប (រួមទាំង ពលកម្មគ្រួសារ ផង)។